## Making appointments for meetings



**នារីតេទូរស័ព្ទទៅកញ្ញា**

កញ្ញា៖ អាឡូ?
នារី៖ អាឡូ កញ្ញា។ ខ្ញុំនារីអ៊ំា។ សុខសប្បាយអត់?
កញ្ញា៖ ខ្ញុំសុខសប្បាយតាស។ ចុះនារី?
នារី៖ ខ្ញុំសុខសប្បាយដែរតាស។ ង៉ៃអាទិត្យហ្នឹង កញ្ញាទំនេរអត់? ទៅញ៉ាំអីជាមួយគ្នាម្ដងអី?
កញ្ញា៖ មានអី។ ម៉ោងម៉ាន? នៅហាងលើកមុនមែន?
នារី៖ ម៉ោងប្រហែលម៉ាណ្ដប់អី ម៉េចដែរ? ទៅហាងទើបបើកថ្មីនៅម្ដុំស្ដាតអូឡាំពិកវិញអី ស្គាល់អត់?
កញ្ញា៖ ម៉ោងម៉ាណ្ដប់បានតាស។ ខ្ញុំអត់ស្គាល់ហាងហ្នុងផង ចាំទៅដល់ស្ដាតអូឡាំពិក ចាំខ្ញុំតេប្រាប់នារី។

**តារាតេទូរស័ព្ទទៅវិបុល**

តារា៖ វិបុល ដឹងថាង៉ៃហ្នឹងគ្នាយើងជុំគ្នាម៉ោងពីរណ្ដប់អត់?
វិបុល៖ ហាក! ក្រែងម៉ោងម៉ាណ្ដប់អ៊េ?
តារា៖ ដូរម៉ោងវិញហើយ។ វិបុលម៉ោម៉ោងពីរណ្ដប់បានអត់?
វិបុល៖ មានអី បានតាស។ កន្លែងអត់ដូរណាអី?
តារា៖ កន្លែងដដែល អត់ដូរអ៊េ។

| | |
|---|---|
| នារី, កញ្ញា | female Cambodian names |
| តេ | to call, to phone |
| អ៊ំា | final particle used for emphasis |
| តាស | final particle affirming the preceding |
| ង៉ៃ | spoken form of ថ្ងៃ = day |
| មានអី | Sure! |
| ម៉ោងម៉ាន? | spoken form of ម៉ោងប៉ុន្មាន? = what time? |
| ម៉ាណ្ដប់ | colloquial form of ដប់មួយ = 11 |
| ម៉ោងប្រហែលម៉ាណ្ដប់អី | around 11 or so |
| ស្ដាតអូឡាំពិក | Stade Olympique (engl.: olympic stadium), a quarter in Phnom Penh |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| ... វិញអី ? | How about ...? / What about ... ? |
| តារា, វិបុល | male Cambodian names |
| គ្នាយើង | our team |
| ពីរណ្ដាប់ | colloquial form of ដប់ពីរ = 12 |
| ហាក! | exclamation expressing surprise, e.g., because something has changed |
| ក្រែង ... អេ៎ ? | Isn't it ... ? |
| ម៉ោ | spoken form of មក = to come |
| អត់ ... ណាអី ? | ..., right? [compare the affirmative equivalent: ... តាសអី ? = ..., right?] |

## Cultural notes

នៅខ្មែរ ការមកយឺតដប់ទៅដប់ប្រាំនាទីនៅពេលណាត់ជួបច្រើនកើតមានជាញឹកញាប់ ពេលខ្លះយឺតរហូតដល់សាមសិបនាទីក៏មាន។ មូលហេតុគឺមកពីទម្លាប់ ឬដោយសារការស្ទះចរាចរណ៍ ដែលកើតឡើងស្ទើរគ្រប់ទីកន្លែងនៅទីក្រុងភ្នំពេញ។

| | |
|---|---|
| ពេលខ្លះ ... ក៏មាន | sometimes even ... |
| ការស្ទះចរាចរណ៍ | traffic jam |
| ស្ទើរគ្រប់ | almost all |

## Additional dialogue

នារី៖ អាឡូ កញ្ញា។ កញ្ញា ខ្ញុំសុំទោស ថ្ងៃអាទិត្យហ្នឹង ខ្ញុំអត់បានទៅអេ៎ ជាប់រវល់ការងារតិច។ ខ្ញុំសុំដូរទៅថ្ងៃសៅរ៍នេះវិញបានអត់ ?

កញ្ញា៖ អត់អីអេ៎ នារី។ ថ្ងៃសៅរ៍ហ្នឹងក៏បានដែរតាស មានអី។ អីចឹង ថ្ងៃសៅរ៍ ម៉ោង ១១ កន្លែងដដែល។

នារី៖ ហ្នឹងហើយ។ សុំទោសណា។ ជួបគ្នាថ្ងៃសៅរ៍។

| | |
|---|---|
| ជាប់រវល់ | to be busy |
| សុំ ... បានអត់ ? | Can I/we ... ? [asking for permission or agreement] |
| អត់អីអេ៎ | colloquial form of អត់អីទេ = no problem, sure |
| ... ក៏បានដែរតាស | ... is also fine |
| អីចឹង | then, so, in that way, like this |
| ហ្នឹងហើយ | yes |
| ណា | final particle to soften a statement or request |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.